# សេចក្តីថ្លែងការណ៍រួម
# ដល់ពេលដែលត្រូវបញ្ចប់និទណ្ឌភាពនៃឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាននៅកម្ពុជា

ភ្នំពេញ ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៥

នៅក្នុងទិវាអន្តរជាតិដើម្បីបញ្ចប់និទណ្ឌភាពនៃឧក្រិដ្ឋកម្មមកលើអ្នកសារព័ត៌មាន យើងជាអង្គការសង្គមស៊ីវិល សមាគមសារព័ត៌មានក្នុងស្រុក និងក្នុងតំបន់ដែលមានរាយនាមដូចខាងក្រោមសូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជាចាត់វិធានការឱ្យបានឆាប់រហ័ស និងជាក់លាក់ដើម្បីធានានូវការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព ឯករាជ្យ និងតម្លាភាព ចំពោះឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ដែលបានប្រព្រឹត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

យោងតាមកំណត់ត្រាដែលបានចងក្រងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា យ៉ាងហោចណាស់អ្នកសារព័ត៌មានចំនួន១៥នាក់ ត្រូវបានសម្លាប់នៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៤មក។ ក្នុងចំណោមនោះអ្នកសារព័ត៌មាន១២នាក់ បានរាយការណ៍អំពីបញ្ហារសើប ដូចជាបញ្ហាបរិស្ថាន និងបញ្ហានយោបាយ ដែលមិនទាន់ទទួលបានយុត្តិធម៌នៅឡើយ។

ការរំលោភសិទ្ធិមនុស្ស និងឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាននៅតែជាកង្វល់កាន់តែខ្លាំងនៅឆ្នាំនេះ។ យោងតាមសមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា) បានកត់ត្រាករណីរំលោភសិទ្ធិលើអ្នកសារព័ត៌-មាន និងស្ថាប័នសារព័ត៌មានសរុបចំនួន ៤៧ ករណី ចាប់ពីខែមករា ដល់ ខែកញ្ញា ឆ្នាំ២០២៥ ។ ក្នុងចំណោម ៤៧ ករណីនេះ មាន៣៧ ករណី ជាការគំរាមគំហែងផ្លូវច្បាប់ សកម្មភាពយាយីតាមផ្លូវច្បាប់ ដែលរួមមានការកោះហៅសួរចម្លើយ ការចាប់ខ្លួន ការឃុំខ្លួននិងការឃុំខ្លួនបណ្តោះអាសន្ន។ បន្ថែមពីនេះទៀតអាជ្ញាបណ្ណសារព័ត៌មានចំនួន៥ ត្រូវបានដកហូត ហើយ៥ ករណី ជាការបំពានលើរាងកាយ។ ការរំលោភបំពានសិទ្ធិអ្នកសារព័ត៌មានភាគច្រើនបង្ករឡើងដោយតួអង្គរដ្ឋ ដែលមានរហូតដល់ ៤១ករណី ក្នុងចំណោមករណីសរុប ៤៧ដែលបានកត់ត្រា។ ទាំងនេះជាការឆ្លុះបញ្ចាំងពីបញ្ហានិទណ្ឌភាពកាន់តែទូលំទូលាយ ដែលអ្នកទទួលខុសត្រូវចំពោះការរំលោភបំពានលើអ្នកសារព័ត៌មានជារឿយៗមិនត្រូវបានដាក់ទោស និងបានធ្វើឱ្យប៉ះពាល់ដល់ទំនុកចិត្តបន្ថែមទៀតនៅក្នុងប្រព័ន្ធយុត្តិធម៌។

ថ្មីៗនេះ អ្នកសារព័ត៌មានចំនួន ៧នាក់ នៅតែបន្តឃុំខ្លួនក្នុងពន្ធនាគារពីបទញុះញង់។ អាជ្ញាធរនៅតែបន្តបដិសេធព័ត៌មានរិះគន់ដោយអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ដោយចាត់ទុកថាវាជា **«ព័ត៌មានញុះញង់»**។ នេះហាក់ដូចជាទម្រង់មួយទៀតនៃការគាបសង្កត់ការរាយការណ៍ដោយឯករាជ្យ។

ជាលទ្ធផល អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន បានចាត់ថ្នាក់ប្រទេសកម្ពុជានៅលេខ ១៦១ ក្នុងចំណោម ១៨០ ប្រទេស នៅក្នុងឆ្នាំ២០២៥ ដោយចាត់ថ្នាក់ប្រទេសកម្ពុជាក្នុងចំណោមប្រទេសចំនួន ៤២ ទៀត ដែលមានស្ថានភាព**«ធ្ងន់ធ្ងរខ្លាំង»**។ ការដៅមុខសញ្ញាលើអ្នកសារព័ត៌មាន ជាពិសេសអ្នកដែលកំពុង

រាយការណ៍ លើប្រធានបទសិទ្ធិមនុស្ស បានធ្វើឱ្យប៉ះពាល់ដល់សេរីភាពខាងការបញ្ចេញមតិ និងសារព័ត៌មាន បង្កជាការគំរាមកំហែងដល់ការទទួលបានព័ត៌មានរបស់សាធារណជន។ ការឃាយី និងការធ្វើទុក្ខបុកម្នេញនេះកាន់តែបង្កផលលំបាកថែមទៀតក្នុងការនាំយកបុគ្គលមានអំណាចមកទទួលខុសត្រូវចំពោះកំហុសរបស់ខ្លួន។ នៅពេលដែលអាជ្ញាធរមិនបានធ្វើការស៊ើបអង្កេតត្រឹមត្រូវនិងផ្តន្ទាទោសអ្នកប្រព្រឹត្តលើអ្នកសារព័ត៌មាននោះជាសារមួយ បង្ហាញថាបទល្មើសបែបនេះត្រូវបានអនុញ្ញាត និងមិនមានទោស។

និទណ្ឌភាពចំពោះបទឧក្រិដ្ឋបែបនេះ មិនមែនកើតមានចំពោះតែអ្នកសារព័ត៌មានប៉ុណ្ណោះទេ។ កង្វះខាតនូវការស៊ើបអង្កេត និងនីតិវិធីព្រហ្មទណ្ឌត្រឹមត្រូវក្នុងករណីឃាតកម្មលើសកម្មជនបរិស្ថាន លោក ឈុត វុទ្ធី សកម្មជនសហជីព លោក ជា វិជ្ជា និងលោក រស់ សុវណ្ណារ៉េត អ្នកវិភាគនយោបាយលោកបណ្ឌិត កែម ឡី កាន់តែបង្ហាញពីការរីករាលដាលនៃវប្បធម៌និទណ្ឌភាពដែលមាននៅក្នុងប្រទេសកម្ពុជាបន្ថែមទៀត។ ករណី រៀបរាប់ខាងលើគ្រាន់តែជាផ្នែកមួយនៃករណីជាច្រើនផ្សេងទៀតនៃការរំលោភបំពានលើអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស សមាជិកនយោបាយជំទាស់ សហជីព និងសកម្មជនផ្សេងៗទៀតប៉ុណ្ណោះដែលករណីពួកគេមិនត្រូវបានដោះស្រាយពីសំណាក់ស្ថាប័នដែលមានតួនាទីការពារសិទ្ធិមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា។

ការវាយប្រហារលើអ្នកសារព័ត៌មាន និងបុគ្គលិកប្រព័ន្ធផ្សព្វផ្សាយគឺជាការវាយប្រហារមកលើយើងទាំងអស់គ្នាព្រោះពួកគេជាសំឡេងដ៏សំខាន់សម្រាប់សាធារណជន។ យើងសូមទាមទារយុត្តិធម៌សម្រាប់អ្នកទាំងឡាយ ដែលសិទ្ធិរបស់គេមិនត្រូវបានអើពើ។ រដ្ឋាភិបាលកម្ពុជាត្រូវតែថ្កោលទោស និងបញ្ចប់នូវនិទណ្ឌភាពចំពោះឧក្រិដ្ឋកម្មលើអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស។

**សេចក្តីថ្លែងការណ៍នេះចូលរួមគាំទ្រដោយ៖**

១. សមាគមសម្ព័ន្ធអ្នកសារព័ត៌មានកម្ពុជា (ខេមបូចា)

២. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក)

៣. មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (ស៊ីស៊ីអាយអឹម)

៤. អង្គការលើកកម្ពស់ប្រព័ន្ធផ្សព្វផ្សាយនិងសារគមនាគមន៍ (អ.ល.ប.ស.)

៥. វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា (CID)

៦. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)

៧. Centre for Independent Journalism (CIJ)-Malaysia

៨. Prachatai (Thailand)

៩. National Union of Journalist of the Philippines (NUJP)

១០. Alliance of Independent Journalists (AJI)-Indonesia

១១. Gerakan Media Merdeka (Geramm)-Malaysia